# ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១៤១

## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន

### យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## គ្រាស់បញ្ញាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ព្រះរាជក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន ដែលសរសេរជាអក្សរកាត់ថា ក.ជ.យ. ដើម្បីជាយន្តការសម្របសម្រួល តាមដាន វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍយុវជន ឱ្យឆ្លើយតបទៅនឹងច្បាប់ស្តីពីការអប់រំនិងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។

## ជំពូកទី២

## សមាសភាព

មាត្រា ២.-

ក.ជ.យ.មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | ប្រធាន |
| - ឧបនាយករដ្ឋមន្ត្រី ១រូបឬច្រើនរូប | អនុប្រធាន |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធានប្រចាំការ |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងការពារជាតិ ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| - រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងធនធានទឹកនិងឧតុនិយម ១រូប | សមាជិក |

- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ១រូប សមាជិក
- រដ្ឋមន្ត្រីឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ២រូប សមាជិក
- ប្រធានឬតំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ សមាជិក
- ប្រធានឬតំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក
- តំណាងអង្គការមិនមែនរដ្ឋាភិបាលឬសមាគមដែលធ្វើការជាយុវជន ហើយដែលក្រសួងយល់ថាជាតម្រូវការចាំបាច់ សមាជិក
- អគ្គលេខាធិការគ.ជ.យ. សមាជិក។

សមាសភាពជាក់ស្តែងរបស់គ.ជ.យ. ត្រូវតែងតាំងដោយអនុក្រឹត្យ។

## ជំពូកទី៣
## តួនាទីនិងភារកិច្ច

**មាត្រា ៣.-**

**គ.ជ.យ.**មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជាយន្តការថ្នាក់ជាតិសម្រាប់សម្របសម្រួលនិងអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា
- អនុម័តផែនការសកម្មភាពជាតិសម្រាប់អនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា

- ជំរុញនិងបញ្ជ្រាបការអភិវឌ្ឍយុវជនទៅក្នុងគោលនយោបាយជាតិនិងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាល
- ណែនាំ ចង្អុលបង្ហាញ និងសម្របសម្រួលដល់ការចូលរួមរបស់យុវជនក្នុងវិស័យសេដ្ឋកិច្ចនិងការសម្រេចបានទូវការអប់រំនិងការបណ្តុះបណ្តាល
- ប្រមូលផ្តុំកម្លាំងយុវជនគ្រប់មជ្ឈដ្ឋាននិងកៀគរធនធានសម្រាប់គាំទ្រនិងអភិវឌ្ឍយុវជនកម្ពុជា
- សិក្សាស្រាវជ្រាវ តាមដានត្រួតពិនិត្យ វាយតម្លៃ ផ្តល់អនុសាសន៍ និងធ្វើរបាយការណ៍ពាក់ព័ន្ធនឹងការអភិវឌ្ឍនិងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់គ.ជ.យ.

**មាត្រា ៤.-**

គ.ជ.យ.ត្រូវជួបប្រជុំសាមញ្ញរៀងរាល់មួយឆមាសម្តង។ ក្នុងករណីមានការចាំបាច់ គ.ជ.យ.អាចប្រជុំវិសាមញ្ញបានតាមការអញ្ជើញរបស់ប្រធាន។ គ.ជ.យ.ត្រូវធ្វើការបូកសរុបរបាយការណ៍ក្នុងមួយឆ្នាំម្តង និងរាយការណ៍ជូនអង្គប្រជុំគ.ជ.យ.ក្រោមអធិបតីភាពរបស់នាយករដ្ឋមន្ត្រីអំពីលទ្ធផលនៃការអនុវត្តកម្មវិធីការងារដែលត្រូវសម្របសម្រួលនិងអនុសាសន៍ដែលគ.ជ.យ.ត្រូវដាក់ចេញ។

របៀបរបបនៃការប្រជុំរបស់គ.ជ.យ.ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់គ.ជ.យ.។

**មាត្រា ៥.-**

គ.ជ.យ.មានសិទ្ធិទាក់ទងជាមួយក្រសួង ស្ថាប័ននានា អង្គការសង្គមស៊ីវិល អង្គការជាតិ អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍនានា ដែលពុំបានចែងក្នុងមាត្រា២នៃព្រះរាជក្រឹត្យនេះ ដើម្បីចូលរួមប្រជុំផ្តល់យោបល់ឬចូលរួមជាអ្នកសង្កេតការណ៍តាមការអញ្ជើញរបស់គ.ជ.យ.។

**មាត្រា ៦.-**

គ.ជ.យ.មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការសម្រាប់ដំណើរការការងារប្រចាំថ្ងៃដែលមានទីតាំងនៅក្រសួងអប់រំ យុវជន និងកីឡា។

អគ្គលេខាធិការដ្ឋាននៃគ.ជ.យ. ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបនិងអគ្គលេខាធិការរងមួយឬច្រើនរូបតាមការចាំបាច់ ដែលត្រូវតែងតាំងដោយព្រះរាជក្រឹត្យឬអនុក្រឹត្យ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគ.ជ.យ. ត្រូវកំណត់ដោយ
[illegible]ក្យ។

មាត្រា ៧.-

គ.ជ.យ. ត្រូវបង្កើតក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត។

សមាសភាព តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគ.ជ.យ.។

មាត្រា ៨.-

គ.ជ.យ.អាចបង្កើតអនុគណៈកម្មការជាតិជំនាញមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារពាក់ព័ន្ធនឹងវិស័យយុវជន។

សមាសភាព តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅរបស់អនុគណៈកម្មការជាតិជំនាញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគ.ជ.យ.។

មាត្រា ៩.-

គ.ជ.យ. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញជាតិឬអ្នកជំនាញអន្តរជាតិមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារ គ.ជ.យ.និងអគ្គលេខាធិការដ្ឋាន។

មាត្រា ១០.-

គ.ជ.យ.មានបទបញ្ជាផ្ទៃក្នុង និមិត្តសញ្ញា និងមានសិទ្ធិប្រើត្រាមួយដោយឡែក។

## ជំពូកទី៥
## ប្រភពធនធានរបស់គ.ជ.យ.

មាត្រា ១១.-

គ.ជ.យ. មានថវិកាដោយឡែករបស់ខ្លួនដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា។

គ.ជ.យ.មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពធនធានផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

នស/រកត.០៣១៣.១៤៦

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ១៣៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៣

**អគ្គលេខាធិការរង ទីស្ដីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**